**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**




# សៀវភៅរបាយការណ៍លទ្ធផល
# ស្ថិតិថ្នាក់ក្រោមជាតិ
## ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ

**រៀបចំដោយៈ**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

**រាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៧**

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូនរបាយការណ៍លទ្ធផលវិភាគ ស្តីពីស្ថិតិថ្នាក់ក្រោមជាតិជំហានទី២ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន ០៤ ខេត្ត គឺខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ។ របាយការណ៍នេះបានប្រមូលនូវទិន្នន័យសំខាន់ៗរួមមាន៖ ផ្នែកស្ថិតិប្រជាសាស្ត្រ កសិកម្ម សេដ្ឋកិច្ច និងផ្នែកស្ថិតិសង្គមកិច្ច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការ និងគោលនយោបាយថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឲ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនេះឡើងតាមអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **សន ស៊ីថន** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំនិងសម្របសម្រួលការងារតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ពេជ ពោធិ** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ឯកឧត្តម លោក ប្រធានមន្ទីរផែនការខេត្ត និងសហការីនៃខេត្តទាំង០៤ ដូចបានរៀបរាប់ខាងលើ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹមថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណៈជនទូទៅ នឹងប្រើប្រាស់របាយការណ៍ដ៏មានសារៈសំខាន់នេះ ៕

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

នេះជាការបោះពុម្ពផ្សាយជាលើកទីពីរ នៃទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើង ដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ដោយមានការសហការពីមន្ទីរផែនការខេត្តទាំងបួន។ សៀវភៅនេះ ផ្តល់នូវទិន្នន័យរួមមាន៖ ស្ថិតិផ្នែកប្រជាសាស្ត្រ សន្តិសុខសង្គម និងសេដ្ឋកិច្ច វិស័យអប់រំ និងសេវាសង្គម សុខាភិបាល និងផ្នែកសិកម្ម ហើយទិន្នន័យនេះសម្រាប់យកមកបម្រើការកសាងផែនការ រៀបចំគោល នយោបាយ កម្មវិធីផ្សេងៗដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

ការបោះពុម្ពផ្សាយនេះរួមមានតារាងជាតួលេខ និងក្រាហ្វិកដែលមានការវិភាគអធិប្បាយខ្លីៗ និង អាចប្រើប្រាស់ជាប្រភពទិន្នន័យព័ត៌មាន សម្រាប់អ្នកប្រើប្រាស់គ្រប់រូបដែលមានចំណាប់អារម្មណ៍ទៅលើ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យនៅក្នុងសៀវភៅនេះត្រូវបានផលិតឡើងដំបូងបំផុតដោយ នាយក ដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ដែល ជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន០៥ខេត្តរួមមកហើយ រួមមាន៖ខេត្តបន្ទាយ មានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ដោយឡែកជំហានទី២ បានចុះស្រង់ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន ០៤ខេត្តបន្តទៀត គឺ ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្ត ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំចងក្រងបោះពុម្ពនូវទិន្នន័យស្ថិតិ ថ្នាក់ក្រោមជាតិ ដ៏មានសារៈសំខាន់ជាលើកទី២នេះ ៕

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន់ លីណា**

# មាតិកា

ទំព័រ


បុព្វកថា……………………………………………………………ii
អារម្ភកថា ……………………………………………………………iii
**ជំពូកទី១ សេចក្តីផ្តើម** ……………………………………………………………១
១.១ សេចក្តីផ្តើម ……………………………………………………………១
១.២ គោលបំណង ……………………………………………………………២
១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ ……………………………………………………………២
១.៤ ការកែច្នៃទិន្នន័យ ……………………………………………………………២
**ជំពូកទី២ វិភាគទិន្នន័យ** ……………………………………………………………៣
២.១ ព័ត៌មានប្រជាសាស្ត្រ ……………………………………………………………៣
២.១.១ ចំនួនប្រជាជន និងគ្រួសារ ……………………………………………………………៣
២.១.២ ព័ត៌មានពីប្រជាជន ……………………………………………………………៥
២.១.៣ ប្រជារាស្ត្រធ្វើការផ្លាស់ប្តូរទីលំនៅ ……………………………………………………………៧
២.១.៤ លំនៅដ្ឋាន ……………………………………………………………១២
២.១.៥ សម្ភារៈបរិក្ខារដែលទាក់ទងការដឹកជញ្ជូនគ្រឿងម៉ាស៊ីន និងយានយន្ត ……………………………………………………………១៧
២.២ អត្រាកំណើត និងមរណភាព……………………………………………………………១៩
២.២.១ អត្រាកំណើត……………………………………………………………១៩
២.២.២ មរណភាព ……………………………………………………………២០
២.៣ ពិការភាពប្រជាជន ……………………………………………………………២៣
២.៣.១ ពិការភាពនៃបុគ្គល ……………………………………………………………២៣
២.៤ ការប្រើប្រាស់ទឹក និងអនាម័យ ……………………………………………………………២៧
២.៥ បរិស្ថាន និងធនធានធម្មជាតិ ……………………………………………………………៣០
២.៦ គ្រោះធម្មជាតិ ……………………………………………………………៣៣
២.៧ សន្តិសុខសង្គម និងសេដ្ឋកិច្ច ……………………………………………………………៣៤
២.៧.១ អសន្តិសុខសង្គម ……………………………………………………………៣៤
២.៧.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ ……………………………………………………………៤០
២.៧.៣ លំហូរវិនិយោគតាមប្រភេទ នៃសកម្មភាពអភិវឌ្ឍន៍ ……………………………………………………………៤៥
២.៨ វិស័យអប់រំ និងសេវាសង្គម ……………………………………………………………៤៦
២.៨.១ ផ្នែកសិក្សាអប់រំ……………………………………………………………៤៦

២.៨.១.១ ចំនួនគ្រឹះស្ថានសិក្សា…………………………………....…….............…......៤៦
២.៨.១.២ ចម្ងាយពីភូមិទៅគ្រឹះស្ថានសិក្សា ……………....……...........…......៤៩
២.៨.២ ផ្នែកសេវាសង្គម ..…………………….…………..………..…………..…......៥១
២.៩ ការស្តាបនាផ្លូវគមនាគមន៍…..……………………...………………………..….....៥៣
២.១០ ផ្នែកសុខាភិបាល……………………………....…………………………........៥៤
២.១០.១ សេវាកម្មសុខភាព………………………....………….........….......៥៤
២.១០.២ ប្រេវ៉ាឡង់ជម្ងឺសំខាន់ៗ………………………....……....……….......៥៦
២.១០.៣ គ្រួសារដែលមានជំងឺអេដស៍ឬផ្ទុកមេរោគអេដស៍ និងកុមារកំព្រា………….......៦១
២.១១ កសិកម្ម………………….....……………......…………………..……….. ៦៣
២.១១.១ គ្រួសារកាន់កាប់តាមទំហំផ្ទៃដី…………………………...........….......៦៣
២.១១.២ ផ្ទៃដីដែលបានដាំដុះ និងផ្ទៃដីប្រមូលផល……………………….....…........៦៥
២.១១.៣ ផ្ទៃដីដាំដំណាំដែលបានស្រោចស្រព……………..……………..….........៦៥
២.១១.៤ ការប្រើប្រាស់ជាតុចូលក្នុងកសិកម្ម………………...…….………….........៦៦
២.១១.៥ ការចិញ្ចឹមបសុសត្វ និងបសុបក្សីរបស់គ្រួសារ……….……………..........៦៨
**ជំពូកទី៣ សន្និដ្ឋាន និងអនុសាសន៍**……………………….....………………៧៣
៣.១ សន្និដ្ឋាន………………………………………………………….……………..........៧៣
៣.២ អនុសាសន៍…………………………………………………….……………..........៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

គម្រោងគាំទ្រស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងមួយថ្មីដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំ ដើម្បីប្រមូលទិន្នន័យស្ថិតិថ្នាក់មូលដ្ឋាន និងធ្វើការវិភាគទៅលើលទ្ធផលទាំងនោះ ស្របតាមការធ្វើផែនការវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋាន គឺរួមមានស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច ដែលត្រូវយកមកចងក្រងវិភាគ។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអ្នកអនុវត្តគម្រោងនេះផ្ទាល់ដែលស្របតាមភារៈកិច្ចរបស់នាយកដ្ឋាន និងតាមសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាម អនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ។

ប្រទេសកម្ពុជាបានបែងចែកជា ៤ តំបន់គឺ តំបន់ទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាបនិងភ្នំ។ ជំហានទី២ ត្រូវបានអនុវត្តទៅលើខេត្តចំនួន ៤ គឺ ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ សម្រាប់ឆ្នាំ២០១៧ ជាខេត្តនៅក្នុងចំណោមរាជធានីខេត្តទាំង ២៥ របស់ប្រទេសកម្ពុជាដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៣ ពីរាជធានីភ្នំពេញ ទៅខេត្តកែប និងខេត្តកំពត ហើយផ្លូវជាតិលេខ៤ ពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ និងខេត្តកោះកុង ។



## ១.២ គោលបំណង

គោលបំណងសំខាន់នៃគម្រោងស្ថិតិថ្នាក់ក្រោមជាតិ គឺវិភាគទិន្នន័យរកឲ្យឃើញនូវបញ្ហាដែលអាចកើតមានឡើងនៅក្នុងមូលដ្ឋាន ដែលមានទិន្នន័យដែលទាក់ទងទៅ ព័ត៌មានប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងកសិកម្ម របស់ខេត្តទាំងបួន។

## ១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើយដោយមន្ត្រីនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការចូលរួមពីមន្ត្រីមន្ទីរផែនការខេត្តទាំងបួន ដោយប្រើប្រាស់កម្រងសំណួរស្ថិតិថ្នាក់ក្រោមជាតិ ចុះសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិដោយផ្ទាល់ គ្រប់ភូមិទាំងអស់ក្នុងខេត្តទាំងបួន ដែលមានរយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១៧។ កាលបរិច្ឆេទយោងគឺរយៈពេល ១២ខែកន្លងមក គឺចាប់ពី ខែ មីនា ឆ្នាំ២០១៦ ដល់ខែ មីនា ឆ្នាំ២០១៧។

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យនេះ គឺត្រូវបានធ្វើការកែច្នៃដោយដៃ និងវាយបញ្ចូលនៅក្នុងកុំព្យូទ័រដោយប្រើប្រាស់តែកម្មវិធី CSPro ប៉ុន្តែ ប្រើប្រាស់បីកម្មវិធី សម្រាប់ធ្វើជាតារាង និងវិភាគទិន្នន័យគឺ CSPro, Excel និង SPSS ។ ចំពោះការវាយអត្ថបទកម្មវិធី Microsoft Word ត្រូវបានយកមកប្រើប្រាស់ផងដែរ ។ ការវាយបញ្ចូលទិន្នន័យ និងវិភាគទិន្នន័យមានរយៈពេល ០២ ខែ គឺចាប់ពីថ្ងៃទី ០១ ខែមេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

# ជំពូក ២
# វិភាគទិន្នន័យ

នៅក្នុងរបាយការណ៍នេះ មានទិន្នន័យដែលទាក់ទងទៅ និងព័ត៌មានប្រជាសាស្រ្ត សេដ្ឋកិច្ច សង្គមកិច្ច ផ្នែកសេវាសុខាភិបាល និងអប់រំ និងផ្នែកកសិកម្ម។

## ២.១ ព័ត៌មានប្រជាសាស្រ្ត

ចំនួនគ្រួសារ និងប្រជាជននៅក្នុងខេត្តទាំង៤ (គិតត្រឹមថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៧) រួមមាន ៖ ខេត្តកំពតមានចំនួន ១៤៥.២៩០ គ្រួសារ និងសរុបចំនួនប្រជាជន ៦១៦.៥៧៤នាក់ ខេត្តកោះកុងចំនួន ២៨.៨៨៩ គ្រួសារ និងសរុបចំនួនប្រជាជន ១៣១.០៩៨ ខេត្តព្រះសីហនុចំនួន ៤០.១៣០ គ្រួសារ និងសរុបចំនួនប្រជាជាជន ១៦០.១៥០ នាក់ និងខេត្តកែបចំនួន ៩.២៧១ គ្រួសារ និងសរុបចំនួនប្រជាជន ៣១.៦០៩ នាក់ តារាងទី(១)។

### ២.១.១ ចំនួនប្រជាជន និងគ្រួសារ

**តារាងទី(១) ចំនួនប្រជាជន និងគ្រួសារ**

| ចំនួនសរុប | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| គ្រួសារ | ១៤៥.២៩០ | ២៨.៨៨៩ | ៤០.១៣០ | ៩.២៧១ |
| ប្រជាជន | ៦១៦.៥៧៤ | ១៣១.០៩៨ | ១៦០.១៥០ | ៣១.៦០៩ |




រូបទី(១) បានបង្ហាញថា៖ **ខេត្តកែប** ក្នុងចំណោមមេគ្រួសារសរុប (៩.២៧១) មានមេគ្រួសារជាស្ត្រី ១៨.២% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ១.៤% **ខេត្តព្រះសីហនុ** ចំណោមមេគ្រួសារសរុប (៤០.១៣០) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៥.៦% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ២.៤% **ខេត្តកោះកុង** ក្នុងចំណោមមេគ្រួសារសរុប (២៨.៨៨៩) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៨.៤% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ៣.៣% **ខេត្តកំពត** ក្នុងចំណោមមេគ្រួសារសរុប(១៤៥.២៩០) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៨.១% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ១.៤% ។

## ២.១.២ ព័ត៌មានពីប្រជាជន

### ក/ គ្រួសារតាមជនជាតិ




រូបទី (២) បានបង្ហាញថា ៖ ចំណោមគ្រួសារសរុបគ្រប់ខេត្ត (ក្នុងនោះមិនរាប់បញ្ចូលភាគរយគ្រួសារដែលជាជនជាតិខ្មែរ យកតែជនជាតិមានភាគរយបីលំដាប់ប៉ុណ្ណោះ) **ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុប (៤០.១៣០) គ្រួសារដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិចិន ៣.៦% ជនជាតិកូរ៉េ ០.៣% **ខេត្តកែប** ចំណោមមេគ្រួសារសរុប (៩.២៧១) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិចិន ២.៨% និងគ្រួសារជាជនជាតិបរទេសផ្សេងទៀត ០.១% និងគ្រួសារជាជនជាតិភាគតិច ០.១% **ខេត្តកំពត** ចំណោមមេគ្រួសារសរុប (១៤៥.២៩០) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិចិន ២.៧% ជនជាតិកូរ៉េ ០.២% និងគ្រួសារជាជនជាតិវៀតណាម ០.២% **ខេត្តកោះកុង** ក្នុងចំណោមមេគ្រួសារសរុប (២៨.៨៨៩) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិចិន ២.៧% ថៃ១.៨% គ្រួសារជាជនជនជាតិវៀតណាម ១.១% និងគ្រួសារជាជនជាតិភាគិតិច ០.៣% ។

## ខ/ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ

រូបទី(៣) ភាគរយមេគ្រួសារតាមស្ថានភាពអាពាហ៍ពិពាហ៍តាមខេត្តទាំងបួន




រូបទី(៣) បានបង្ហាញថា ៖ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារក្នុងចំណោមគ្រួសារសរុបក្នុងខេត្តទាំងបួនមាន៖ **ខេត្តកែប** ក្នុងចំណោមមេគ្រួសារសរុប (៩.២៧១) ក្នុងនោះមានមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នាមាន ៨៤.៣% មេម៉ាយ/ពោះម៉ាយមាន ១០.៩% មិនដែលរៀបការមាន ២.៩% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ១.៩% **ខេត្តកំពត** ចំណោមមេគ្រួសារសរុប (១៤៥.២៩០) ក្នុងនោះមានមេគ្រួសារដែលបានរៀបការនិងរស់នៅជាមួយគ្នាមាន ៨៤.៤% មេម៉ាយ/ពោះម៉ាយមាន ១០.៨% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ០.៨% **ខេត្តកោះកុង** ចំណោមមេគ្រួសារសរុប (២៨.៨៨៩) ក្នុងនោះមានមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នាមាន ៨៨.៤% និងមេម៉ាយ/ពោះម៉ាយមាន ៩.៨% **ខេត្តព្រះសីហនុ** ក្នុងចំណោមមេគ្រួសារសរុបចំនួន (៤០.១៣០) ក្នុងនោះមានមេគ្រួសារដែលបានរៀបការនិងរស់នៅជាមួយគ្នាមាន ៨៥.៤% មេម៉ាយ/ពោះម៉ាយមាន ១១.៩% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ០.៩% ។

## ២.១.៣ ប្រជាពលរដ្ឋធ្វើការផ្លាស់ប្តូរទីលំនៅ

### ក/ គ្រួសារធ្វើចំណាកស្រុកចេញនិងចូល

**រូបទី(៤) គ្រួសារធ្វើការផ្លាស់ប្តូរទីលំនៅតាមខេត្តទាំងបួន**




រូបទី(៤) បានបង្ហាញថា៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់គ្រួសារចំណោមគ្រួសារសរុបគ្រប់ខេត្ត រួមមាន៖ **ខេត្តកែប**ក្នុងចំណោមគ្រួសារសរុបចំនួន(៩.២៧១) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកចំនួន ៧៩៧ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកចំនួន ១៨៧ គ្រួសារ **ខេត្តកំពត** ក្នុងចំណោមគ្រួសារសរុបចំនួន(១៤៥.២៩០) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកចំនួន ៨.១២៩ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកចំនួន ៤៨៥ គ្រួសារ **ខេត្តកោះកុង** ក្នុងចំណោមគ្រួសារសរុបចំនួន(២៨.៨៨៩) មានគ្រួសារធ្វើចំណាកស្រុកចំនួន ២.៨៥៦ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកចំនួន ២.៩៤៤ គ្រួសារ **ខេត្តព្រះសីហនុ**ក្នុងចំណោមគ្រួសារសរុបចំនួន(៤០.១៣០) ក្នុងនោះមានមានគ្រួសារធ្វើ ចំណាកស្រុកចំនួន ២.២៨ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកចំនួន ២៨០ គ្រួសារ ។ សរុបសេចក្តីមកការធ្វើចំណាកស្រុករបស់គ្រួសារខ្ពស់ គឺខេត្តកំពត និងខេត្តកោះកុង បន្ទាប់មកខេត្តព្រះសីហនុ និងខេត្តកែប។

## ខ/ មូលហេតុដែលគ្រួសារធ្វើចំណាកស្រុក ក្នុងនិងក្រៅប្រទេស

រូបទី(៥) គ្រួសារស្វែងទៅរកការងារធ្វើក្នុងប្រទេស និងក្រៅប្រទេសតាមខេត្តទាំងបួន




រូបទី(៥) បានបង្ហាញថា៖ ស្ថានភាពការធ្វើចំណាកស្រុករបស់គ្រួសារក្នុងចំណោមគ្រួសារសរុបគ្រប់ខេត្តរួមមាន៖ **ខេត្តកែប**មានចំនួនគ្រួសារសរុប(៩.២៧១) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើនឹង ២៧៦ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ១.៧១៦គ្រួសារ **ខេត្តកំពត**ក្នុងចំណោមគ្រួសារសរុបចំនួន (១៤៥.២៩០) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើនឹង ១៥.៣៦២ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៥.៣២១ គ្រួសារ **ខេត្តកោះកុង** ក្នុងចំណោមគ្រួសារសរុបចំនួន (២៨.៨៨៩) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើនឹង ២.២៦១ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៣.៥៧៨ គ្រួសារ និង**ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុបចំនួន (៤០.១៣០) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើនឹង ១.១៨២ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៩៣៦ គ្រួសារ។

### គ/ ពលករចំណាកស្រុកក្នុង និងក្រៅប្រទេស

តារាងទី(២) អ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេសតាមខេត្តទាំងបួន

| ពលករចំណាកស្រុក | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| នៅក្នុងប្រទេស | ៣៥.០០៤ | ៥.៨៥៦ | ២.៣៧៣ | ២.០៧៩ |
| នៅក្រៅប្រទេស | ១៣.០៨៩ | ៣.០៨៣ | ២.១០២ | ៣១៥ |
| **សរុប** | **៤៨.០៩៣** | **៨.៩៣៩** | **៤.៤៧៥** | **២.៣៩៤** |

តារាងទី (២) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកក្នុង និងក្រៅប្រទេសរួមមាន៖ **ខេត្តកែប** ក្នុងចំណោមពលករសរុបចំនួន(២.៣៩៤) ក្នុងនោះមានពលករស្វែងរកការងារក្រៅប្រទេសចំនួន ៣១៥ នាក់ និងពលករធ្វើការងារក្នុងប្រទេសចំនួន ២.០៧៩ នាក់ **ខេត្តកំពត** ក្នុងចំណោមពលករសរុបចំនួន (៤៨.០៩៣) ក្នុងនោះមានពលករស្វែងរកការងារក្រៅប្រទេសចំនួន១៣.០៨៩ នាក់ និងពលករធ្វើការងារក្នុងប្រទេសចំនួន ៣៥.០០៤ នាក់ **ខេត្តកោះកុង** ក្នុងចំណោមពលករសរុបចំនួន(៨.៩៣៩) ក្នុងនោះមានពលករស្វែងរកការងារក្រៅប្រទេសចំនួន ៣.០៨៣ នាក់ និងពលករធ្វើការងារក្នុងប្រទេសចំនួន ៥.៨៥៦ នាក់ ចុងក្រោយ គឺ**ខេត្តព្រះសីហនុ**ក្នុងចំណោមពលករសរុបចំនួន(៤.៤៧៥) ក្នុងនោះមានពលករស្វែងរកការងារក្រៅប្រទេសចំនួន ២.១០២ នាក់ និងពលករធ្វើការងារក្នុងប្រទេសមានចំនួន ២.៣៧៣ នាក់។ សរុបសេចក្តីមកក្នុងចំណោមខេត្តទាំងបួន ខេត្តដែលមានពលករធ្វើចំណាក់ស្រុកក្រៅប្រទេសច្រើនជាងគេគឺ**ខេត្តកំពត** ។

## ឃ/ ពលករស្វែងរកការងារក្នុង និងក្រៅប្រទេសបែងចែកតាមភេទ

### ១/ ក្នុងប្រទេស




រូបទី(៦) បានបង្ហាញថា៖ ស្ថានភាពពលករចំណាក់ស្រុករកការងារធ្វើក្នុងប្រទេសរបស់**ខេត្តកែប** ក្នុងចំណោមពលករសរុបចំនួន(២.០៧៩នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៤៤.១% **ខេត្តកំពត** ក្នុងចំណោមពលករសរុបចំនួន (៣៥.០០៤នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៤៧.៧% **ខេត្តកោះកុង** ក្នុងចំណោមពលករសរុបចំនួន (៥.៨៥៦នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៥៤.៧% **ខេត្តព្រះសីហនុ** ក្នុងចំណោមពលករសរុបចំនួន(២.៣៧៣នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៤៤.៥% ។ សរុបមកក្នុងខេត្តទាំងបួនចំនួនភាគរយពលការីនីដែលធ្វើចំណាក់ស្រុករកការងារធ្វើក្នុងប្រទេសច្រើនជាងគេគឺខេត្តកោះកុងមានចំនួន ៥៤.៧%។

## ២/ ក្រៅប្រទេស




រូបទី(៧) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុករកការងារក្រៅប្រទេស របស់ **ខេត្តកែប** ក្នុងចំណោមពលករសរុបចំនួន (៣១៥នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៣៣% **ខេត្តកំពត** ក្នុងចំណោមពលករសរុបចំនួន (១៣.០៨៩នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៤១% **ខេត្តកោះកុង** ក្នុងចំណោមពលករសរុបចំនួន (៣.០៨៣នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៤៣.៦% **ខេត្តព្រះសីហនុ** ក្នុងចំណោមពលករសរុបចំនួន (២.១០២នាក់) ក្នុងនោះមានភាគរយពលការីនីស្មើនឹង ៣៧.៥% ។

## ២.១.៤ លំនៅដ្ឋាន

### ក/ ប្រភេទនៃដំបូលផ្ទះរបស់គ្រួសារ

### តារាងទី (៣) ប្រភេទនៃដំបូលផ្ទះ

| ប្រភេទនៃដំបូលផ្ទះ | កំពត | | កោះកុង | | ព្រះសីហនុ | | កែប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| បេតុង | ២.៨៥៧ | ២.១ | ២៩៩ | ១.១ | ២.៦១២ | ៧.៦ | ៦២៤ | ៧.៩ |
| ក្បឿង | ៤៤.៣៩៦ | ៣២.៧ | ៣៩២ | ១.៥ | ១.២៨០ | ៣.៧ | ៨៨៥ | ១១.២ |
| ស័ង្កសី / ហ្វីប្រូ | ៧៩.៥៣៥ | ៥៨.៦ | ២៣.៨១២ | ៨៩.២ | ២៨.៨៨០ | ៨៤.២ | ៦.១២០ | ៧៧.៧ |
| ប្រក់ស្លឹក | ៧.៣២៦ | ៥.៤ | ១.០៧៧ | ៤.០ | ៦៨៤ | ២.០ | ៧៨ | ១.០ |
| ផ្សេងទៀត | ១.៦៥៦ | ១.២ | ១.១៣០ | ៤.២ | ៨៣៩ | ២.៤ | ១៦៨ | ២.១ |
| **សរុប** | **១៣៥.៧៧០** | **១០០** | **២៦.៧១០** | **១០០** | **៣៤.២៩៥** | **១០០** | **៧.៨៧៥** | **១០០** |

តារាងទី (៣) បានបង្ហាញថា ៖ ភាគរយខ្ពស់នៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្តាលខេត្តទាំងបួនគឺៈ នៅក្នុង**ខេត្តកោះកុង** ដែលមានផ្ទះរបស់ប្រជាពលរដ្ឋដែលមានដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ ៨៩.២% បន្ទាប់មក **ខេត្តព្រះសីហនុ** ៨៤.២% **ខេត្តកែប** ៧៧.៧% និង**ខេត្តកំពត** ៥៨.៦%។ ចំណែកផ្ទះដំបូលប្រក់អំពីស្លឹកវិញមានភាគរយទាបជាបគេ គឺនៅក្នុង**ខេត្តកែប** ១% ទន្ទឹមនឹងនោះផ្ទះដំបូលប្រក់អំពីស្លឹកដែលមានភាគរយខ្ពស់ជាងគេគឺក្នុង**ខេត្តកំពត** ៥.៤%។

## ខ/ ការប្រើប្រាស់អគ្គិសនីតាមប្រភេទនៃដំបូលផ្ទះ

រូបទី (៨) ភាគរយគ្រួសារមានអគ្គិសនីប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្តទាំងបួន




រូបទី (៨) បានបង្ហាញថា៖ ស្ថានភាពការប្រើប្រាស់អគ្គិសនីគ្រប់ខេត្តទាំងបួនរបស់គ្រួសារដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមានជាង ៩០% នៅក្នុង**ខេត្តកោះកុង** ៨៤.២% នៅក្នុង**ខេត្តព្រះសីហនុ** ៧៥.១% នៅក្នុង**ខេត្តកែប** និង ៥៦.៣% នៅក្នុង**ខេត្តកំពត** បន្ទាប់មកសូម្បីតែផ្ទះដំបូលប្រក់ស្លឹករបស់គ្រួសារក៏ មានអគ្គិសនីប្រើប្រាស់ដែរដូចជានៅក្នុងខេត្តកំពត ២.១% ខេត្តកោះកុង ១.១% ខេត្តព្រះសីហនុ ១.៥% និងខេត្តកែប ០.៧% ។ ដូចនេះបញ្ជាក់ឲ្យឃើញថាការប្រើប្រាស់អគ្គិសនីនៅតាមបណ្ដាលខេត្តទាំងបួន មានគ្រប់តាមប្រភេទនៃដំបូលផ្ទះរបស់គ្រួសារ។

## គ/ គ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ

រូបទី(៩) ភាគរយនៃគ្រួសារមានទូរទស្សន៍ប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្តទាំងបួន




រូបទី(៩) បានបង្ហាញពីគ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ស្របជាមួយ និងការប្រើប្រាស់អគិសនីមានគ្រប់ខេត្តទាំងបួនរបស់គ្រួសារក្នុង **ខេត្តកោះកុង** ខ្ពស់ជាងគេដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមានរហូតទៅដល់ ៨៨.៩% និងគ្រួសារដែលមានផ្ទះដំបូលប្រក់ស្លឹកមានត្រឹមតែ ១.៥% ប៉ុណ្ណោះ ។ ដោយឡែក **ខេត្តព្រះសីហនុ** វិញគ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ មានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមានរហូតទៅដល់ ៨៤.១% និងគ្រួសារដែលមានផ្ទះដំបូលប្រក់ស្លឹកមានត្រឹមតែ ១% ។ ចំណែកឯ **ខេត្តកែប** មានគ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ មានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមានរហូតទៅដល់ ៧០.៤% និងគ្រួសារដែលមានផ្ទះដំបូលប្រក់ស្លឹកមានតែ ០.៦% ។ **ខេត្តកំពត** មានគ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់មានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមាន ៥៦.៩% និងគ្រួសារដែលមានផ្ទះដំបូលប្រក់ស្លឹកមាន ២.៥%។

## ឃ/ គ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃជំបូលផ្ទះ

រូបទី (១០) ភាគរយនៃគ្រួសារមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃជំបូលផ្ទះ និងតាមខេត្តទាំងបួន




រូបទី (១០) បានបង្ហាញថា ៖ ស្ថានភាពគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ស្រដៀងគ្នាជាមួយនិងគ្រួសារដែលមានអគ្គិសនីប្រើប្រាស់នៅតាមផ្ទះផងដែរ។ ប៉ុន្តែគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ភាគច្រើនតែចំពោះគ្រួសារដែលមានដំបូលធ្វើអំពីស័ង្កសី/ហ្វីប្រូ (២៧.៧% នៅ**ខេត្តកែប ខេត្តកំពត** ៥៥.៨% **ខេត្តកោះកុង** ៨២.២% និង**ខេត្តព្រះសីហនុ** ៧០.២%)។ ដោយឡែកគ្រួសារដែលមានផ្ទះដំបូលបេតុងក៏មានកុំព្យូទ័រប្រើប្រាស់ផងដែរដូចជានៅខេត្តកំពតមាន ១១.៥% ខេត្តកោះកុងមាន ៧.២% ខេត្តព្រះសីហនុ មាន ១៨.៤% និងខេត្តកែប ៦២.៦% ។

## ង/ គ្រួសារដែលមានកុំទូរស័ព្ទដៃប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ

រូបទី(១១) ភាគរយនៃគ្រួសារមានទូរស័ព្ទដៃប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្តទាំងបួន




រូបទី (១១) បានបង្ហាញថា៖ ភាគរយដែលខ្ពស់ជាងរបស់គ្រួសារ នៃប្រភេទដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្តាលខេត្តទាំងបួន ដែលមានគ្រួសារមានផ្ទះដំបូលស័ង្កសី/ហ្វីប្រូ និងមានទូរស័ព្ទប្រើប្រាស់ភាគរយខ្ពស់ជាងគេគឺ**ខេត្តកោះកុង** ៨៨.៦% បន្ទាប់មក**ខេត្តព្រះសីហនុ** ៨៤.៤% **ខេត្តកែប** ៧៧% និង **ខេត្តកំពត** ៥៨.៣% សូម្បីតែគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹក ក៏មានទូរស័ព្ទប្រើប្រាស់ដៃរដូចជានៅក្នុងខេត្តកំពតមាន ៤.៧% ខេត្តកោះកុង ១.៥% ខេត្តព្រះសីហនុ ១.៤% និងខេត្តកែប ៧% ដូច្នេះហើយសបញ្ជាក់អោយឃើញថាវិស័យសេវាទូរគមនាគមន៏នៅក្នុងបណ្តាលខេត្តទាំងបួន មានការីចម្រើនគួរអោយកត់សំគាល់។

## ២.១.៥ សម្ភារៈបរិក្ខារដែលទាក់ទងការដឹកជញ្ជូនគ្រឿងម៉ាស៊ីន និងយានយន្ត

តារាងទី(៤) ចំនួននៃបរិក្ខារតាមប្រភេទ និងតាមខេត្តទាំងបួន

| ប្រភេទនៃបរិក្ខា | កំពត | | កោះកុង | | ព្រះសីហនុ | | កែប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ឧបករណ៍កសិកម្ម និងនេសាទ | ២៦.០១០ | ២០ | ៤.៣២៧ | ២០ | ៣.២០១ | ៨ | ១.០៧៩ | ១៣ |
| សេវាដឹកជញ្ជូន | ៧.៤៨៨ | ៦ | ១.២៨៧ | ៦ | ៤.៨១៥ | ១២ | ៧៧១ | ៩ |
| មធ្យោបាយប្រើប្រាស់ផ្ទាល់ខ្លួន | ៩៧.៨៣៩ | ៧៥ | ១៦.០៦៦ | ៧៤ | ៣១.២២៧ | ៨០ | ៦.២៨៦ | ៧៧ |
| **សរុប** | ១៣១.៣៣៧ | ១០០ | ២១.៦៨០ | ១០០ | ៣៩.២៤៣ | ១០០ | ៨.១៣៦ | ១០០ |

តារាងទី(៤) បានបង្ហាញថា៖ ភាគរយនៃប្រភេទបរិក្ខារកសិកម្ម និងនេសាទ របស់ប្រជាពលរដ្ឋដែលមាន តាមបណ្តាលខេត្តទាំងបួន លើគ្រឿងម៉ាស៊ីនកសិកម្ម និងនេសាទមានក្នុងខេត្តកំពត ២០% ខេត្តកោះកុង ២០% ខេត្តព្រះសីហនុ ៨% និងខេត្តកែប ១៣% ។ ចំណែកសេវាដឹកជញ្ជូនវិញ មានក្នុងខេត្តកំពត ៦% ខេត្តកោះកុង ៦% ខេត្តព្រះសីហនុ ១២% និងខេត្តកែប ៩% ។ មធ្យោបាយប្រើប្រាស់ផ្ទាល់ខ្លួន មានភាគរយខ្ពស់ជាងគេមានក្នុង(**ខេត្តព្រះសីហនុ** ៨០% បន្ទាប់មក**ខេត្តកែប** ៧៧% **ខេត្តកំពត** ៧៥% និង**ខេត្តកោះកុង** ៧៤%)។

តារាងទី (៥) ចំនួននៃគ្រួសារដែលមានបរិក្ខារតាមប្រភេទ និងតាមខេត្តទាំងបួន

| ប្រភេទនៃបរិក្ខា | កំពត | | កោះកុង | | ព្រះសីហនុ | | កែប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ឧបករណ៍កសិកម្ម និង នេសាទ | ២៥.៦៤២ | ២០ | ៤.២៤៣ | ២០ | ៣.១៧៨ | ៨ | ១.០៧៩ | ១៣ |
| សេវាដឹកជញ្ជូន | ៧.៣៦០ | ៦ | ១.២៨៨ | ៦ | ៤.៨១៥ | ១២ | ៧៦៨ | ៩ |
| មធ្យោបាយប្រើប្រាស់ផ្ទាល់ខ្លួន | ៩៧.១៩៦ | ៧៥ | ១៥.៥៨៦ | ៧៤ | ៣១.២១៤ | ៨០ | ៦.២៧៦ | ៧៧ |
| **សរុប** | ១៣០.១៩៨ | ១០០ | ២១.១១៧ | ១០០ | ៣៩.២០៧ | ១០០ | ៨.១២៣ | ១០០ |

តារាងទី(៥) បានបង្ហាញថា៖ ក្នុងចំណោមខេត្តទាំងបួន ភាគរយនៃគ្រួសារដែលមានមធ្យោបាយប្រើប្រាស់ផ្ទាល់ខ្លួនខ្ពស់ជាងមានក្នុងខេត្តព្រះសីហុន ៨០% ខេត្តកែប ៧៧% ខេត្តកំពត ៧៥% និងខេត្តកោះកុង ៧៤% ។ ដូច្នេះហើយបញ្ជាក់អោយឃើញថា ខេត្តព្រះសីហនុជាខេត្តមួយដែលមានរីកចម្រើនខ្លាំងក្នុងរយៈពេលចុងក្រោយនេះ។ ចំណែកឯកភាគរយនៃគ្រួសារដែលមានឧបករណ៍កសិកម្ម និងនេសាទប្រើប្រាស់ដូចជាមានក្នុងខេត្តកំពត ២០% ខេត្តកោះកុង ២០% ខេត្តព្រះសីហនុ ៨% និងខេត្តកែប១៣% ។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១ អត្រាកំណើត

**ក/ ទីកន្លែងទារកកើតក្នុងរយៈពេល១២ខែកន្លងមក**

តារាង (៦) ចំនួន និងភាគរយទារកក្នុងរយៈពេល១២ខែកន្លងមកតាមខេត្ត

| ទីកន្លែងកើត | កំពត | | កោះកុង | | ព្រះសីហនុ | | កែប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| មន្ទីរពេទ្យរដ្ឋ | ៦.៦១០ | ៩៧.៣ | ១.៧៤២ | ៨៤.៤ | ១.៨០៣ | ៩០.០ | ២៨៥ | ៧០.០ |
| មន្ទីរពេទ្យឯកជន | ១០២ | ១.៥ | ៥៧ | ២.៨ | ១៩១ | ៩.៥ | ៨៦ | ២១.១ |
| ឆ្មបបុរាណ | ៨ | ០.១ | ២៥២ | ១២.២ | ៩ | ០.៤ | - | - |
| ផ្សេងៗ | ៧៦ | ១.១ | ១៤ | ០.៧ | - | - | ៣៦ | ៨.៨ |
| **សរុប** | **៦.៧៩៦** | **១០០** | **២.០៦៥** | **១០០** | **២.០០៣** | **១០០** | **៤០៧** | **១០០** |

តារាងទី(៦)បានបង្ហាញថា៖ ភាគរយរបស់ទារកកើតក្នុងរយៈពេល១២ខែកន្លងមកតាមបណ្តាលខេត្តទាំងបួនមាន៖ **ខេត្តកែប**សរុបចំនួន(៤០៧នាក់) ក្នុងនោះមានមន្ទីរពេទ្យរដ្ឋ ៧០% មន្ទីរពេទ្យឯកជន ២១.១% **ខេត្តកំពត**សរុបចំនួន(៦.៧៩៦នាក់) ក្នុងនោះមានមន្ទីរពេទ្យរដ្ឋ ៩៧.៣% មន្ទីរពេទ្យឯកជន ១.៥% ឆ្មបបុរាណ ០.១% **ខេត្តកោះកុង**សរុបចំនួន(២.០៦៥នាក់) ក្នុងនោះមានមន្ទីរពេទ្យរដ្ឋ ៨៤.៤% មន្ទីរពេទ្យឯកជន ២.៨% ឆ្មបបុរាណ ១២.២% **ខេត្តព្រះសីហនុ**សរុបចំនួន(២.០០៣នាក់) ក្នុងនោះមានមន្ទីរពេទ្យរដ្ឋ ៩០% មន្ទីរពេទ្យឯកជន ៩.៥% និងឆ្មបបុរាណ ០.៤% ។

### ខ/ ទារកកើតក្នុងរយៈពេល១២ខែកន្លងមកតាមភេទ

**រូបទី (១២) ចំនួនទារកកើតរយៈពេល១២ខែកន្លងមកតាមភេទ និងតាមខេត្ត**




រូបទី(១២) បានបង្ហាញថា៖ ក្នុងខេត្តទាំងបួនអត្រាភាគរយទារកភេទស្រីដែលខ្ពស់ជាងទារកភេទប្រុសគេគឺ**ខេត្តព្រះសីហនុ** (ទារកភេទស្រី ៥៧.២% និងទារកភេទប្រុស ៤២.៨%) ភាគរយទារកភេទស្រីខ្ពស់បន្ទាប់**ខេត្តកំពត** (ទារកភេទស្រី ៥៤% និងទារកភេទប្រុស ៤៦%) បន្ទាប់មក**ខេត្តកែប** (ទារកភេទស្រី ៥៤.១% និងទារកភេទប្រុស ៤៥.៩%) ចុងក្រោយ**ខេត្តកោះកុង** (ទារកភេទស្រី ៤៦.១% និងទារកភេទប្រុស ៤៣.៩%)។

## ២.២.២ មរណៈភាព

### ក/ ជម្ងឺ

តារាង(៧) មូលហេតុនៃការស្លាប់រយៈពេល១២ខែកន្លងមកតាមខេត្តទាំងបួន

| មូលហេតុចម្បងនៃការស្លាប់ | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| ១- ជម្ងឺ | ២,០០១ | ៣៣ | ៤៥៤ | ១១៥ |
| ២- គ្រោះថ្នាក់ចរាចរណ៍ | ១៦៧ | ១៩ | ៥៩ | ១៥ |
| ៣- លង់ទឹក | ៤៥ | - | - | ១ |
| ៤- ពស់ចឹក | ១ | - | - | - |
| ៥- ឃាតកម្ម | ៥ | ១ | ១ | ១ |
| ៦- ផ្សេងៗ | ២២៨ | ៧០ | ១៦ | ៣២ |
| **សរុប** | **២,៤៤៧** | **១២៣** | **៥៣០** | **១៦៤** |

តារាងទី(៧) បានបង្ហាញថាៈ ចំនួនអ្នកស្លាប់សរុបក្នុង**ខេត្តកែប** (១៦៤នាក់) ក្នុងនោះស្លាប់ដោយសារជម្ងឺ ១១៥នាក់ ប្រហែល ៧០.១% **ខេត្តកំពត** អ្នកស្លាប់សរុបចំនួន (២.៤៤៧នាក់) ក្នុងនោះស្លាប់ដោយសារជម្ងឺ ២.០០១នាក់ ប្រហែល ៨១.៨% **ខេត្តកោះកុង** ចំនួនអ្នកស្លាប់សរុប (១២៣នាក់) ក្នុងនោះស្លាប់ដោយសារជម្ងឺ ៣៣នាក់ ប្រហែល ២៦.៨% **ខេត្តព្រះសីហនុ** ចំនួនអ្នកស្លាប់សរុប (៥៣០នាក់) ក្នុងនោះស្លាប់ដោយសារជម្ងឺ ៤៥៤នាក់ ប្រហែល ៨៥.៧% នៃចំនួនអ្នកស្លាប់ប្រចាំខេត្តនីមួយៗ ។




## ខ/ គ្រោះថ្នាក់ចរាចរណ៍ និងលង់ទឹក



តារាងទី (៧) និងរូបទី (១៤) បានបង្ហាញថា៖ អ្នកស្លាប់សរុបមានចំនួន ១៦៤នាក់ ក្នុង**ខេត្តកែប** ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៩.១% និងលង់ទឹក ០.៦% **ខេត្តកំពត** មានចំនួន ២.៤៤៧ នាក់ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៦.៨% និងលង់ទឹក ១.៨% **ខេត្តកោះកុង** មានចំនួន១២៣ នាក់ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ១៥.៤% **ខេត្តព្រះសីហនុ** មានចំនួន ៥៣០នាក់ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ១១.១% ។ សរុបសេចក្ដីមកក្នុង**ខេត្តកោះកុង**ក្នុងចំណោមខេត្តទាំងបួន ភាគរយនៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ខ្ពស់ជាងគេ។

### គ/ អ្នកស្លាប់រយៈពេល១២ខែកន្លងមកតាមភេទ

**រូបទី (១៥) ភាគរយអ្នកស្លាប់នៅរយៈពេល១២ខែកន្លងមកតាមភេទ និងតាមខេត្ត**




រូបទី (១៥) បានបង្ហាញថា៖ នៅក្នុងខេត្តកែបមានអ្នកស្លាប់សរុបចំនួន ១៦៤នាក់ ក្នុងនោះប្រុស ៦២.២% និងស្រី ៣៧.៨% ខេត្តកំពត មានចំនួន ២.៤៤៧នាក់ ក្នុងនោះប្រុស ៥៤.៣% និងស្រី ៤៥.៧% ខេត្តកោះកុង មានចំនួន ១២៣នាក់ ក្នុងនោះប្រុស ៥៦.៩% និងស្រី ៤៣.១% និងខេត្តព្រះសីហនុ មានចំនួន ៥៣០នាក់ ក្នុងនោះប្រុស ៥៥.៨% និងស្រី ៤៤.២% ។ សរុបមកចំនួនភាគរយអ្នកស្លាប់ប្រុសក្នុងខេត្តទាំងបួនមានភាគរយខ្ពស់ជាងស្រី។

## ២.៣ ពិការភាពប្រជាជន

### ២.៣.១ ពិការភាពនៃបុគ្គល

តារាង(៨)ពិការភាពនៃបុគ្គលតាមខេត្តទាំងបួន

| បរិយាយ | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| បុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន | ៤.៥៤៦ | ២៣៧ | ៩៦៨ | ៥៨៧ |
| មនុស្សចាស់ដែលគ្មានអ្នកមើលថែ | ៥១៦ | ២៣ | ៨៩ | ២៨ |
| អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ) | ២៧៨ | ១១៥ | ១៤២ | ៥៣ |
| បុគ្គលពិការដែលមានប្រភពចំណូល | ៧១៣ | ៣៨ | ១៣៥ | ៩៧ |
| បុគ្គលពិការដែលគ្មានចំណូល | ១.៤៨៣ | ៣៣ | ៣៥០ | ២៤៤ |

### ក/ ការរងគ្រោះដោយសារគ្រាប់មីន




រូបទី(១៦) បានបង្ហាញថា៖ អ្នករងគ្រោះដោយសារគ្រាប់មីនដែលមានចំនួនច្រើនជាគេក្នុង**ខេត្តកំពត** ៤.៥៤៦នាក់ ក្នុងនោះប្រុស ៨២.៨% និងស្រី ១៧.២% បន្ទាប់មក**ខេត្តព្រះសីហនុ** ៩៦៨នាក់ ក្នុងនោះប្រុស ៨៨.៨% និងស្រី ១១.២% **ខេត្តកែប** មានចំនួន ៥៨៧នាក់ ក្នុងនោះប្រុស ៨៩.៣% និងស្រី ១០.៧% ចុងក្រោយ**ខេត្តកោះកុង** ចំនួន២៣៧នាក់ ក្នុងនោះប្រុស៧៨.៣% និងស្រី ២១.៧% ។

## ខ/ មនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់




រូបទី (១៧) បានបង្ហាញអោយឃើញថា៖ មនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៥១៦នាក់ ក្នុង**ខេត្តកំពត** ក្នុងនោះមានប្រុស ១៨.៣% និងស្រី ៨១.៧% **ខេត្តកែប** សរុបចំនួន ២៨នាក់ ក្នុងនោះមានប្រុស ១៧% និងស្រី ៨៣% **ខេត្តកោះកុង** សរុបចំនួន ២៣នាក់ ក្នុងនោះមានប្រុស ៤៧% និងស្រី ៥៣% និង**ខេត្តព្រះសីហនុ** មានចំនួនសរុប ៨៩នាក់ ដោយក្នុងនោះមានប្រុស ២៧.៥% និងស្រី ៧២.៥% ។ សរុបមកភាគរយនៃចំនួនបុរសដែលជាមនុស្សចាស់ដែលគ្មានអ្នកមើលថែ ឬគ្រួសារផ្គត់ផ្គង់ក្នុងខេត្តនីមួយៗ មានអត្រាភាគរយខ្ពស់ជាងគេ។

## គ/ អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ)

រូបទី (១៨) ភាគរយអនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ)




រូបទី (១៨) បានបង្ហាញថា៖ អនីតិជនដែលពិការភាពមានអាយុក្រោម១៨ឆ្នាំក្នុង**ខេត្តកំពត** សរុបចំនួន ២៧៨នាក់ ក្នុងនោះមានប្រុស៥៥.៣% និងស្រី៤៤.៧% **ខេត្តកែប** សរុបចំនួន ៥៣នាក់ ប្រុស ៦១.៩% និងស្រី ៣៨.១% **ខេត្តកោះកុង** សរុបចំនួន ១១៥ ប្រុស ៥២.៦% និងស្រី ៤៧.៤% **ខេត្តព្រះសីហនុ** សរុបចំនួន ១៤២នាក់ ក្នុងនោះមានចំនួនប្រុស ៥៤.៨% និងស្រី ៤៥.២% ។

## ឃ/ ប្រភពចំណូលរបស់ជនពិការ

រូបទី (១៩) ភាគរយប្រភពចំណូលរបស់ជនពិការតាមខេត្ត



រូបទី (១៩) បានបង្ហាញថាៈ ចំនួនជនដែលពិការសរុបមាន ៣៤១នាក់ នៅខេត្តកែប ក្នុងនោះមានចំណូល ៥៩.៧% និងគ្មានចំណូល ៤០.៣% ខេត្តកំពត មានចំនួន ២.១៩៦នាក់ ក្នុងនោះមានចំណូល ៤៨.៨% និងគ្មានចំណូល ៥១.២% ខេត្តកោះកុង មានចំនួន ៧១នាក់ ក្នុងនោះមានចំណូល ៥៤.១% និងគ្មានចំណូល ៤៥.៩% និងចុងក្រោយខេត្តព្រះសីហនុ មានចំនួន ៤៨៥នាក់ ក្នុងនោះមានចំណូល ៥៨.១% និងគ្មានចំណូល ៤១.៩% ។

## ២.៤ ការប្រើប្រាស់ទឹក និងអនាម័យ

តារាងទី(៩) ប្រភពទឹកប្រើប្រាស់ដោយគ្រួសារ

| បរិយាយ | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| គ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) | ២៣.២១៩ | ៩.៦២៣ | ១៧.២២២ | ៤៤១ |
| គ្រួសារដែលមានអណ្តូង | ៤៣.៩៨១ | ៧.៩៨៦ | ១៨.៤០៨ | ៣.៥៨៤ |
| គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ | ១៣.៩៤០ | ៧៦២ | ១០០ | ៧៣០ |
| គ្រួសារបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ | ៣២.៨៥៨ | ២.៥២៩ | ១.៤៩៤ | ២.៩០០ |
| គ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន | ៥៧.៨៧៣ | ១៤.៧៥០ | ២៧.០០៣ | ៥.៨៤០ |
| **គ្រួសារសរុប** | **១៤៥.២៩០** | **២៨.៨៨៩** | **៤០.១៣០** | **៩.២៧១** |

### ក/ ការប្រើប្រាស់ទឹក




រូបទី (២០) បានបង្ហាញថា៖ **ខេត្តកែប** ក្នុងចំណោមគ្រួសារសរុប (៩.២៧១គ្រួសារ) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ៥.៨% គ្រួសារដែលមានអណ្តូង ៤៦.៨% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ៩.៥% និងគ្រួសារដែលបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៣៧.៩% **ខេត្តកំពត** ក្នុងចំណោមគ្រួសារសរុប (១៤៥.២៩០គ្រួសារ) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ២០.៤% គ្រួសារដែលមានអណ្តូង ៣៨.៦% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១២.២% និងគ្រួសារដែលបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ២៨.៨% **ខេត្តកោះកុង**

ក្នុងចំណោមគ្រួសារសរុប(២៨.៨៨៩គ្រួសារ) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ៤៦% គ្រួសារដែលមានអណ្តូង ៣៨.២% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ៣.៦% និងគ្រួសារដែលបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ១២.១% **ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុប(៤០.១៣០គ្រួសារ) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ៤៦.៣% គ្រួសារដែលមានអណ្តូង ៤៩.៥% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ០.៣% និងគ្រួសារដែលបានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៤% ។

## ខ/ អនាម័យ

**រូបទី (២១) ភាគរយនៃគ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួនតាមខេត្តទាំងបួន**




រូបទី (២១) បានបង្ហាញថា៖ **ខេត្តកែប** ក្នុងចំណោមគ្រួសារសរុប (៩.២៧១គ្រួសារ) ក្នុងនោះមានគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ ៦៣%**ខេត្តកំពត** ក្នុងចំណោមគ្រួសារសរុប (១៤៥.២៩០ គ្រួសារ) ក្នុងនោះមានគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ ៣៩.៨% **ខេត្តកោះកុង** ក្នុងចំណោមគ្រួសារសរុប (២៨.៨៨៩គ្រួសារ) ក្នុងនោះមានគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ ៥១.១% **ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុប (៤០.១៣០គ្រួសារ) ក្នុងនោះមានគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ ៦៧.៣% ។

## គ/ គ្រួសារដែលគ្មានផ្ទះសម្បែង




រូបទី (២២) បានបង្ហាញថា៖ **ខេត្តកែប** ក្នុងចំណោមគ្រួសារសរុប (៩.២៧១គ្រួសារ) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ២.២% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.១% **ខេត្តកំពត** ក្នុងចំណោមគ្រួសារសរុប (១៤៥.២៩០គ្រួសារ) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ១.៤% និងនិងគ្រួសារដែលគ្មានផ្ទះសម្បែង ០.២% **ខេត្តកោះកុង** ក្នុងចំណោមគ្រួសារសរុប (២៨.៨៨៩គ្រួសារ) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ៣% និងនិងគ្រួសារដែលគ្មានផ្ទះសម្បែង ០.១% **ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុប (៤០.១៣០គ្រួសារ) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ៣.៣% និងនិងគ្រួសារដែលគ្មានផ្ទះសម្បែង ០.៤% ។

## ២.៥ បរិស្ថាន និងធនធានធម្មជាតិ

### ក/ ទីតាំងរបស់ផ្ទៃដីចោលសម្រាម




រូបទី(២៣) បានបង្ហាញថា៖ ក្នុងចំណោមខេត្តទាំងបួនខេត្តដែលមានផ្ទៃដីចោលសម្រាមធំជាងគេ គឺ**ខេត្តកោះកុង** ៥៣ ហិកតា បន្ទាប់មក**ខេត្តកែប** ៣៣ ហិកតា **ខេត្តកំពត** ២៩ ហិកតា និង**ខេត្តព្រះសីហនុ** ១៥ ហិកតា ។

### ខ/ ទីតាំងរបស់ផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម



រូបទី(២៤) បានបង្ហាញថាៈ **ខេត្តកែប** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម ១៣ ហិកតា **ខេត្តកំពត** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម ៨ ហិកតា **ខេត្តកោះកុង** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម ២១ ហិកតា និង**ខេត្តព្រះសីហនុ** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម ១០ ហិកតា ។

### គ/ ការចម្អិនអាហាររបស់គ្រួសារ




រូបទី (២៥) បានបង្ហាញថាៈ **ខេត្តកែប** ក្នុងចំណោមគ្រួសារសរុប (៩.២៧១គ្រួសារ) ក្នុងនោះគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ១៧% **ខេត្តកំពត** ក្នុងចំណោមគ្រួសារសរុប (១៤៥.២៩០គ្រួសារ) ក្នុងនោះគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៦៩% **ខេត្តកោះកុង** ក្នុងចំណោមគ្រួសារសរុប (២៨.៨៨៩គ្រួសារ) ក្នុងនោះគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៣៧% និង**ខេត្តព្រះសីហនុ** ក្នុងចំណោមគ្រួសារសរុប (៤០.១៣០គ្រួសារ) ក្នុងនោះគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៦៦% ។

### ឃ/ ធនធានធម្មជាតិ

តារាងទី (១០) ធនធានធម្មជាតិ

| បរិយាយ | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| ព្រៃឈើគ្របដណ្តប់ | ១៣.៦៥៦ | ៦៥៦ | ៥.១៧០ | ៣៧១ |
| ការដាំកូនឈើ | ៣៨៦ | ៤ | ០ | ៤ |
| ការកាប់ឆ្ការព្រៃ | ១០៧ | ៣៦ | ១.០៦០ | ០ |

តារាងទី(១០) បានបង្ហាញអោយដឹងថា៖ **ខេត្តកែប** មានព្រៃឈើគ្របដណ្តប់ចំនួន ៣៧១ ហិកតា ការដាំកូនឈើឡើងវិញ ៤ ហិកតា និងពុំមានការកាប់ឆ្ការព្រៃទេ **ខេត្តកំពត** មានព្រៃឈើគ្របដណ្តប់ចំនួន ១៣.៦៥៦ ហិកតា ការដាំកូនឈើឡើងវិញ ៣៨៦ ហិកតា និងការកាប់ឆ្ការព្រៃ ១០៧ ហិកតា **ខេត្តកោះកុង** មានព្រៃឈើគ្របដណ្តប់ចំនួន ៦៥៦ ហិកតា ការដាំកូនឈើឡើងវិញ ៤ ហិកតា និងការកាប់ឆ្ការព្រៃ ៣៦ ហិកតា **ខេត្តព្រះសីហនុ** មានព្រៃឈើគ្របដណ្តប់ចំនួន ៥.១៧០ ហិកតា ការដាំកូនឈើឡើងវិញពុំមាន និងការកាប់ឆ្ការព្រៃចំនួន ១.០៦០ ហិកតា ។

## ២.៦ គ្រោះធម្មជាតិ

### ក/ គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ

តារាង (១១) គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិតាមខេត្តទាំងបួន

| គ្រោះធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|---|
| កំពត | ១.០៩៧ | ១១ | ២.៧៤៦ | ៩៣ |
| កោះកុង | - | - | ៣០២ | ៣៥ |
| ព្រះសីហនុ | - | - | - | ២៣ |
| កែប | - | - | - | ២១ |

តារាងទី (១១) បានបង្ហាញអោយដឹងថាៈ គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ ក្នុងនោះ**ខេត្តកំពត** រងគ្រោះដោយសារទឹកជំនន់ ១.០៩៧ គ្រួសារ រងគ្រោះដោយសារដីបាក់ឬស្រុត ១១ គ្រួសារ គ្រោះរាំងស្ងួត ២.៧៤៦ គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៩៣ គ្រួសារ ។ **ខេត្តកោះកុង** រងគ្រោះរាំងស្ងួតចំនួន ៣០២ គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៣៥ គ្រួសារ ។ **ខេត្តព្រះសីហនុ** រងគ្រោះដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ២៣ គ្រួសារ ។ **ខេត្តកែប** រងគ្រោះដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ២១ គ្រួសារ ។

### ខ/ ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ

តារាង (១២) ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិតាមខេត្តទាំងបួន(គិតជាហិកតា)

| គ្រោះធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|---|
| កំពត | ៥០៣ | - | ២.០៥០ | ១៩០ |
| កោះកុង | - | - | ៥ | ៥ |
| ព្រះសីហនុ | - | - | - | ៧៨០ |
| កែប | - | - | - | ២២ |

តារាងទី (១២) បានបង្ហាញអោយដឹងថាៈ ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ ក្នុងនោះខេត្តកំពត រងគ្រោះដោយសារទឹកជំនន់ ៥០៣ ហិកតា រងគ្រោះដោយគ្រោះរាំស្ងួត ២.០៤០ ហិកតា និងរងគ្រោះដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ១៩០ ហិកតា ។ ខេត្តកោះកុង ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះរាំងស្ងួត ៥ ហិកតា និងដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៥ ហិកតា ។ ខេត្តព្រះសីហនុ ផ្ទៃដីដែលមានផលប៉ះពាល់ដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៧៨០ ហិកតា ។ ខេត្តកែប ដីដែលមានផលប៉ះពាល់ដោយសារខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ២២ ហិកតា ។

## ២.៧ សន្តិសុខសង្គម និង សេដ្ឋកិច្ច

### ២.៧.១ អសន្តិសុខសង្គម

បញ្ហាសន្តិសុខសង្គមសំដៅលើការករណី លួច ឆក់ ប្លន់ ចាប់ជំរិត និងឧក្រិដ្ឋកម្ម ប្រើប្រាស់គ្រឿងញៀន ជម្លោះដីធ្លីនៅក្នុងមូលដ្ឋាន ។ ចំពោះករណីទាំងអស់នេះទោះបីជាមានចំនួនកើតឡើងច្រើនករណីក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែខិតខំដោះស្រាយបានមួយចំនួនធំដែរ ដូច្នេះតួលេខបានបង្ហាញដូចខាងក្រោមនេះ។

**ក/ ករណីលួច**




រូបទី(២៦) នេះបានបង្ហាញអោយឃើញថាៈ **ខេត្តកំពត** មានករណីលួច ឆក់ និងប្លន់សរុប ២៧៤ ករណី ក្នុងនោះដោយស្រាយបានចំនួន ១៨៧ ករណី **ខេត្តកោះកុង** មានករណីលួច ឆក់ និងប្លន់ សរុប ៥០ ករណី ក្នុងនោះបានធ្វើការដោះស្រាយបានចំនួន ៣៣ ករណី **ខេត្តព្រះសីហនុ** មានករណីលួច ឆក់

និងប្លន់សរុប ១៣៣ ករណី ក្នុងនោះបានធ្វើការដោះស្រាយបានចំនួន ៨១ ករណី **ខេត្តកែប** មានករណីលួច ឆក់ និងប្លន់សរុប ១៧ ករណី ក្នុងនោះបានធ្វើការដោះស្រាយបានចំនួន ៨ ករណី ។

### ខ/ ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម




រូបទី( ២៧) បានបង្ហាញថា៖ **ខេត្តកំពត** មានអំពើឃាតកម្ម ប្លន់ និងឧក្រិដដ្ឋកម្មសរុបចំនួន ១៣ ករណី បានដោះស្រាយ ១៣ ករណី សល់ ១ករណីទៀតពុំទាន់បានដោះស្រាយ ។ **ខេត្តកោះកុង** មានអំពើឃាតកម្ម ប្លន់ និងឧក្រិដដ្ឋកម្មសរុបចំនួន ១ ករណី និងបានដោះស្រាយរួចរាល់។ **ខេត្តព្រះសីហនុ** មានអំពើឃាតកម្ម ប្លន់ និងឧក្រិដដ្ឋកម្មសរុបចំនួន ១ ករណីដែរ ហើយក៏បានដោះស្រាយរួចរាល់ផងដែរ។ **ខេត្តកែប** មានអំពើឃាតកម្ម ប្លន់ និងឧក្រិដដ្ឋកម្មសរុបចំនួន ១ ករណីដែរ ហើយក៏បានដោះស្រាយរួចរាល់ផងដែរ។

## គ/ ជម្លោះដីធ្លី

រូបទី (២៨) ចំនួនករណីជម្លោះដីធ្លីដែលកើតមានតាមខេត្តទាំងបួន




រូបទី(២៨) បានបង្ហាញថា៖ ករណីជម្លោះដីធ្លីក្នុង**ខេត្តកំពត** សរុបចំនួន ៣៩១ ករណី ក្នុងនោះអាជ្ញាធរបានធ្វើការដោះស្រាយជូនប្រជាពរដ្ឋបាន ៣៣៤ ករណី។ **ខេត្តកោះកុង** មានករណីជម្លោះដីធ្លីសរុបចំនួន ១១០ ករណី បានធ្វើការដោះស្រាយបាន ៧៥ ករណី។ **ខេត្តព្រះសីហនុ** មានករណីជម្លោះដីធ្លីសរុបចំនួន ១២៦ ករណី បានធ្វើការដោះស្រាយបាន ៦៧ ករណី។ **ខេត្តកែប** មានករណីជម្លោះដីធ្លីសរុបចំនួន ២៦ បានធ្វើការដោះស្រាយបាន ២៤ ករណី។

## ឃ/ ការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ

រូបទី (២៩) ចំនួនករណីដែលប្រជាពលរដ្ឋទាស់ទែងគ្នាតាមខេត្តទាំងបួន



រូបទី(២៩) បានបង្ហាញថា៖ ករណីជម្លោះទាស់ទែងគ្នារបស់ប្រជាពលរដ្ឋក្នុង**ខេត្តកំពត** សរុបចំនួន ៤៧២ ករណី ដោះស្រាយបាន ៤២៦ ករណី។ **ខេត្តកោះកុង** ករណីជម្លោះទាស់ទែងគ្នារបស់ប្រជាពលរដ្ឋសរុបចំនួន ១៦៥ ករណី ដោះស្រាយបាន ១១៣ ករណី។ **ខេត្តព្រះសីហនុ** មានករណីជម្លោះទាស់ទែងគ្នារបស់ប្រជាពលរដ្ឋសរុបចំនួន ២២០ ករណី ដោះស្រាយបានចំនួន ១៥៩ ករណី ។ **ខេត្តកែប** មានករណីជម្លោះទាស់ទែងគ្នារបស់ប្រជាពលរដ្ឋសរុបចំនួន ៣៦ ករណី និងដោះស្រាយបានចំនួន ៣៤ ករណី។

**ង/ បទឃាតកម្ម**

**រូបទី (៣០) ចំនួនករណីបទឃាតកម្មតាមខេត្តទាំងបួន**




រូបទី(៣០) បានបង្ហាញថា៖ ករណីបទឃាតកម្មដែលបានកើតឡើងនៅ**ខេត្តកំពត** សរុបចំនួន ២ ករណី ក្នុងនោះអាជ្ញាធរបានធ្វើការដោះស្រាយបានទាំង ២ ករណី ។ **ខេត្តកោះកុង** សរុបចំនួនបទឃាតកម្មចំនួន ១៥ ករណី ក្នុងនោះអាជ្ញាធរបានធ្វើការដោះស្រាយបានទាំង ១៥ ករណីដូចគ្នា។ **ខេត្តព្រះសីហនុ** មានបទឃាតកម្មសរុបចំនួន ១៩ ករណីដោយក្នុងនោះអាជ្ញាធរបានដោះស្រាយបានតែ ៣ ករណីប៉ុណ្ណោះ ដោយឡែកនៅក្នុង**ខេត្តកែប** វិញពុំមានបទឃាតកម្មកើតឡើងទេ។

## ច/ ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន

រូបទី (៣១) ភាគរយនៃគ្រួសារប្រើប្រាស់អំពើហិង្សា និងគ្រឿងញៀនតាមខេត្តទាំងបួន




រូបទី(៣១) បានបង្ហាញថា៖ ក្នុងចំណោមគ្រួសារនៅ**ខេត្តកំពត** (១.០០០គ្រួសារ) ក្នុងនោះមានចំនួន ៣ គ្រួសារបានប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង ១ គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន។ **ខេត្តកោះកុង** ក្នុងចំណោម (១.០០០គ្រួសារ) មានគ្រួសារចំនួន ៦ គ្រួសារ បានប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង ១ គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន ។ **ខេត្តព្រះសីហនុ** ក្នុងចំណោម (១.០០០ គ្រួសារ) មាន ៤ គ្រួសារ បានប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង ១ គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន **ខេត្តកែប** ក្នុងចំណោម (១.០០០គ្រួសារ) មាន ២ គ្រួសារប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង ១ គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន ។

### ឆ/ ស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងជួញដូរ




រូបទី(៣២) បានបង្ហាញថា៖ ក្នុងចំណោមស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរក្នុង**ខេត្តកំពត** ចំនួន ១២ ករណី (ការចាប់រំលោភ ៦ ករណី និងការជួញដូរ ៦ ករណី) ។ **ខេត្តកោះកុង** ក្នុងចំណោមស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរ ៥ ករណី ( ការចាប់រំលោភ ៤ ករណី និងការជួញដូរ ១ ករណី) ។ **ខេត្តព្រះសីហនុ** ពុំមានការស្ត្រីដែលបានរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរទេ ។ **ខេត្តកែប** មានស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ ចំនួន ១ ករណី និងគ្មានការជួញដូរទេ។

### ជ/ ស្ត្រីរងគ្រោះដោយសារការចាប់រំលោភនិងជួញដូរតាមក្រុមអាយុ



រូបទី (៣៣) បានបង្ហាញថាៈ ក្នុងចំណោមស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរក្នុង**ខេត្តកំពត** ចំនួន ១២ ករណី (ការរំលោភបំពាន់ផ្លូវភេទអាយុក្រោម១៨ឆ្នាំចំនួន ៣ ករណី) **ខេត្តកោះកុង** ក្នុងចំណោមស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរ ៥ ករណី (ការរំលោភបំពាន់ផ្លូវភេទអាយុក្រោម១៨ឆ្នាំចំនួន ៣ ករណី) **ខេត្តព្រះសីហនុ**ពុំមានការស្ត្រីដែលបានរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ និងការជួញដូរទេ ។ **ខេត្តកែប** មានស្ត្រីរងគ្រោះដោយសារការរំលោភបំពាន់ផ្លូវភេទ ចំនួន ១ ករណី (ការរំលោភបំពាន់ផ្លូវភេទអាយុក្រោម១៨ឆ្នាំចំនួន ១ ករណី) ។

## ២.៧.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ




រូបទី (៣៤) បានបង្ហាញពីសកម្មភាពអាជីវកម្មចម្បងរបស់គ្រួសារក្រៅពីរបរកសិកម្មមាននៅក្នុង **ខេត្តកំពត** មានចំនួន ២១.០២១ គ្រួសារ **ខេត្តកោះកុង** មានចំនួន ៤.០២៦ គ្រួសារ **ខេត្តព្រះសីហនុ** មានចំនួន ៦.៣៦៤ គ្រួសារ និង**ខេត្តកែប** មានចំនួន ១.៣៤៩ គ្រួសារ។

## ក/ ម៉ាស៊ីនកិនស្រូវ




សកម្មភាពអាជីវកម្មម៉ាស៊ីនកិនស្រូវ រូបទី (៣៥) បានបង្ហាញថា៖ **ខេត្តកំពត** មានចំនួន ២០៣៧ គ្រួសារ **ខេត្តកោះកុង** មានចំនួន ៣៤៩ គ្រួសារ **ខេត្តព្រះសីហនុ** មានចំនួន ៩២ គ្រួសារ និង**ខេត្តកែប** មានចំនួន ១១ គ្រួសារ ។

## ខ/ ផ្នែកសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន




សកម្មភាពអាជីវកម្មផ្នែក សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានរូបទី (៣៦) **ខេត្តកំពត** ១៣២ គ្រួសារ **ខេត្តកោះកុង** ១០៩ គ្រួសារ **ខេត្តព្រះសីហនុ** ៣៦៨ គ្រួសារ និង**ខេត្តកែប**មានចំនួន ៧៧ គ្រួសារ ។

## គ/ ផ្នែកអាជីវកម្មជួសជុលម៉ាស៊ីនគ្រប់ប្រភេទ




សកម្មភាពអាជីវកម្មផ្នែកជួសជុលម៉ាស៊ីនគ្រប់ប្រភេទ រូបទី (៣៧) បង្ហាញថា៖ **ខេត្តកំពត** មានចំនួន ១.២៨២ គ្រួសារ ។ **ខេត្តកោះកុង** មានចំនួន ២២១ គ្រួសារ ។ **ខេត្តព្រះសីហនុ** ៣៨៤ គ្រួសារ និង**ខេត្តកែប** មានចំនួន ៨១ គ្រួសារ ។

## ឃ/ ផ្នែកអាជីវកម្មគ្រឿងសំណង់ និងសង្ហារឹមធ្វើពីឈើ




សកម្មភាពអាជីវកម្មផ្នែកលក់គ្រឿងសំណង់ និងសង្ហារឹមធ្វើពីឈើ រូបទី (៣៨) **ខេត្តកំពត** មានចំនួន ៣៣១ គ្រួសារ **ខេត្តកោះកុង** មានចំនួន ៧៨ គ្រួសារ **ខេត្តព្រះសីហនុ** ១១៧ គ្រួសារ និង**ខេត្តកែប** ២០ គ្រួសារ ។

## ង/ ផ្នែកអាជីវកម្មលក់គ្រឿងទេស និងភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក




រូបទី (៣៩) បានបង្ហាញថា៖ សកម្មភាពអាជីវកម្មផ្នែកលក់គ្រឿងទេស និងភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក ក្នុងខេត្តទាំងបួនរួមមាន**ខេត្តកំពត** មានចំនួន ២.៨៦៨ គ្រួសារ **ខេត្តកោះកុង** មានចំនួន ៦១៤ គ្រួសារ **ខេត្តព្រះសីហនុ** ១.០៥៩ គ្រួសារ និង**ខេត្តកែប** ១៤៧ គ្រួសារ ។

## ច/ គ្រួសារមានស្ថានីយ៍ចាក់ប្រេងឥន្ធនៈគ្រប់កម្រិត



រូបទី (៤០) បានបង្ហាញថា៖ សកម្មភាពអាជីវកម្មគ្រួសារដែលមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិត **ខេត្តកំពត** ២.៤៧៤ គ្រួសារ **ខេត្តកោះកុង** ៤០៩ គ្រួសារ **ខេត្តព្រះសីហនុ** ៦៤៨ គ្រួសារ និង**ខេត្តកែប** ២០២ គ្រួសារ ។

**ឆ/ តូបកាត់សក់ ឬអ៊ុតសក់ និងអាជីវកម្មផ្សេងទៀត**




រូបទី (៤១) បានបង្ហាញថា៖ សកម្មភាពអាជីវកម្មគ្រួសារដែលមានតូបកាត់សក់ ឬអ៊ុតស៊ក់ និងអាជីវកម្មផ្សេងទៀត ដែលក្នុង**ខេត្តកំពត** មានចំនួន ១.៥៥០ គ្រួសារ **ខេត្តកោះកុង** មានចំនួន ២៤៩ គ្រួសារ **ខេត្តព្រះសីហនុ** មានចំនួន ៥២៤ គ្រួសារ និង**ខេត្តកែប** ១៣២ គ្រួសារ។

## ២.៧.៣ លំហូរវិនិយោគតាមប្រភេទ នៃសកម្មភាពអភិវឌ្ឍន៍

រូបទី (៤២) ចំនួនសកម្មភាពអភិវឌ្ឍន៍តាមខេត្តទាំងបួន




